២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៥-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៦-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៧-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៨-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៦២៥.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៦០៥ (បទស្លូកប៉ាន់) មាត្រា ៦០៦ (បទជំនួញឥទ្ធិពលសកម្ម) និងមាត្រា ៦០៧ (បទសម្លុតគំរាម) នៃក្រមនេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើន ដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃ ក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៧-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

# មាតិកាទី ៤
# ការប៉ះពាល់ដល់ទំនុកចិត្តសាធារណៈ
## ជំពូកទី ១
## ការក្លែងបន្លំ
### ផ្នែកទី ១
### ការក្លែងបន្លំឯកសារ

**មាត្រា ៦២៦.-** និយមន័យនៃការក្លែងបន្លំ

ការក្លែងបន្លំ គឺជាការធ្វើឱ្យខូចខាតដោយចេតនានូវការពិត ដែលសម្តែងចេញជាក់ស្តែងនៅក្នុងលិខិត ឬតាមមធ្យោបាយដទៃទៀតនៃការសម្តែងនូវគំនិត កាលបើមានគ្រប់លក្ខខណ្ឌដូចតទៅ :

១-ការធ្វើឱ្យខូចខាតនេះមានកម្មវត្ថុ ឬអាចមានអានុភាពធ្វើជាភស្តុតាងនៃសិទ្ធិ ឬនៃអំពើដែលមានផលវិបាកគតិយុត្ត ។

២-ការធ្វើឱ្យខូចខាតនេះអាចបណ្តាលឱ្យមានព្យសនកម្ម ។

**មាត្រា ៦២៧.-** ទោសដែលត្រូវអនុវត្ត

ការក្លែងបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦២៨.-** បទប្រើប្រាស់លិខិតក្លែង

ការប្រើប្រាស់លិខិតក្លែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦២៩.-** បទក្លែងបន្លំឯកសារសាធារណៈ

ការក្លែងបន្លំប្រព្រឹត្តនៅក្នុងលិខិតយថាភូត ឬការក្លែងបន្លំប្រព្រឹត្តនៅក្នុងឯកសារដែលចេញឱ្យដោយរាជការសាធារណៈ ដើម្បីធ្វើការកត់សម្គាល់សិទ្ធិ អត្តសញ្ញាណ ឬឋានៈ ឬដើម្បីយល់ព្រមផ្តល់ការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៦៣០.-** បទប្រើប្រាស់ឯកសារសាធារណៈក្លែង

ការប្រើប្រាស់ឯកសារក្លែងដែលមានចែងក្នុងមាត្រា ៦២៩ (បទក្លែងបន្លំឯកសារសាធារណៈ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៦៣១.-** បទផ្តល់ឯកសារដោយទុច្ចរិត

អំពើផ្តល់ដល់អ្នកដទៃដោយទុច្ចរិត នូវឯកសារដែលចេញដោយរាជការសាធារណៈ ដើម្បីធ្វើការកត់សម្គាល់សិទ្ធិ អត្តសញ្ញាណ ឬឋានៈ ឬដើម្បីយល់ព្រមផ្តល់ការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៦៣២.-** បទសុំឱ្យផ្តល់ឯកសារដោយទុច្ចរិត

អំពើដែលសុំដោយទុច្ចរិតឱ្យរាជការសាធារណៈចេញ នូវឯកសារសម្រាប់ធ្វើការកត់សម្គាល់សិទ្ធិ អត្តសញ្ញាណ ឬឋានៈ ឬយល់ព្រមផ្តល់ការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

**មាត្រា ៦៣៣.-** បទផ្តល់សេចក្តីប្រកាសដោយភូតកុហក

អំពើផ្តល់សេចក្តីប្រកាសដោយភូតកុហកដល់រាជការសាធារណៈ ដើម្បីទទួលបានវិភាជន៍ ការបើកប្រាក់ ឬអត្ថប្រយោជន៍ដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដាក់

ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

**មាត្រា ៦៣៤.-** បទផ្ដល់លិខិតបញ្ជាក់មិនពិត

ក្រៅពីករណីដែលបញ្ញត្តក្នុងផ្នែកនេះ អំពើដែលធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្រ ដែលរៀបរាប់ពីការណភាព ដែលតាមជាក់ស្ដែងមិនមែនជាការពិត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល ។

**មាត្រា ៦៣៥.-** បទក្លែងលិខិតបញ្ជាក់

អំពើក្លែងបន្លំលិខិតបញ្ជាក់ ឬវិញ្ញាបនបត្រ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល ។

**មាត្រា ៦៣៦.-** បទប្រើប្រាស់លិខិតបញ្ជាក់មិនពិត ឬលិខិតបញ្ជាក់ក្លែងក្លាយ

ការប្រើប្រាស់លិខិតបញ្ជាក់មិនពិត ឬក្លែងក្លាយ ឬវិញ្ញាបនបត្រមិនពិត ឬក្លែងក្លាយ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល ។

**មាត្រា ៦៣៧.-** បទស៊ីសំណូកដោយអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល អំពើរបស់បុគ្គលដែលប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួនដោយទទួចសុំ ឬយល់ព្រមទទួលអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្ររៀបរាប់ពីការណភាព ដែលតាមជាក់ស្ដែង មិនមែនជាការពិត ។

**មាត្រា ៦៣៨.-** បទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជា

ប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល អំពើប្រគល់អំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ឱ្យបុគ្គលណាម្នាក់ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្ររៀបរាប់ពីការណភាព ដែលតាមជាក់ស្តែង មិនមែនជាការពិត ។

**មាត្រា ៦៣៩.-** បទស៊ីសំណូកដោយសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល អំពើរបស់គ្រូពេទ្យ ឬបុគ្គលដែលជាសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដែលទទូចសុំ ឬយល់ ព្រមទទួល អំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្ររៀបរាប់ពីការណភាព ដែលតាមជាក់ស្តែងមិនមែនជាការពិត ។

**មាត្រា ៦៤០.-** បទស្លូកប៉ាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល អំពើប្រគល់អំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ដល់គ្រូពេទ្យ ឬបុគ្គលដែលជាសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្រ រៀបរាប់ពីការណភាព ដែលតាមជាក់ស្តែងមិនមែនជាការពិត ។

**មាត្រា ៦៤១.-** ការអនុវត្តបទមជ្ឈិមនៃមាត្រា ៦៣៩ និងមាត្រា ៦៤០ ចំពោះគ្រប់វិជ្ជាជីវៈខាងវេជ្ជសាស្ត្រ

បទប្បញ្ញត្តិនៃមាត្រា ៦៣៩ (បទស៊ីសំណូកដោយសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) និងមាត្រា ៦៤០ (បទស្លូកប៉ាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) នៃក្រមនេះ

ត្រូវអនុវត្តទៅលើគ្រប់បុគ្គលដែលប្រកបវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ។

**មាត្រា ៦៤២.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងមាត្រា ៦៣២ (បទសុំឱ្យផ្តល់ឯកសារដោយទុច្ចរិត) មាត្រា ៦៣៨ (បទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទា ដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) និងមាត្រា ៦៤០ (បទសូកប៉ាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) នៃក្រមនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៦៤៣.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## មាត្រា ៦៤៤.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៦៣៨ (បទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) និងមាត្រា ៦៤០ (បទសូកប៉ាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ ដោយមាត្រា ១៧៣ (ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ) នៃ ក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៧-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៨-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្ដីសម្រេច) នៃក្រមនេះ ។

៩-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ផ្នែកទី ២

## រូបិយវត្ថុ និងរូបិយបណ្ណក្លែង

**មាត្រា ៦៤៥.-** បទក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល

ការក្លែងបន្លំក្រដាសប្រាក់ ឬកាសដែលជារូបិយវត្ថុមានតម្លៃនីត្យានុកូលនៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត ។

**មាត្រា ៦៤៦.-** បទក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល

ការក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល ដែលបោះពុម្ពផ្សាយដោយស្ថាប័នបរទេស ឬអន្តរជាតិ ដែលមាននីតិសម្បទា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ៦៤៧.-** បទដាក់ឱ្យធ្វើចរាចរណ៍រូបិយវត្ថុ និងរូបិយបណ្ណក្លែង

ការដាក់ឱ្យធ្វើចរាចរណ៍រូបិយវត្ថុ ឬរូបិយបណ្ណក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ (បទក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល) និងមាត្រា ៦៤៦ (បទក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តជាក្រុមមានការចាត់តាំង ។

**មាត្រា ៦៤៨.-** បទសន្និធិរូបិយវត្ថុ និងរូបិយបណ្ណក្លែង

អំពើដឹកជញ្ជូន ឬសន្និធិរូបិយវត្ថុ ឬរូបិយបណ្ណក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ (បទក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល) និងមាត្រា ៦៤៦ (បទក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល) នៃក្រមនេះ ដើម្បីយកទៅដាក់ឱ្យធ្វើចរាចរណ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តជាក្រុមមានការចាត់តាំង ។

**មាត្រា ៦៤៩.-** បទក្លែងបន្លំរូបិយវត្ថុ និងរូបិយបណ្ណដែលអស់តម្លៃនីត្យានុកូល

ការក្លែងបន្លំរូបិយវត្ថុ ឬរូបិយបណ្ណដែលអស់តម្លៃនីត្យានុកូលនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦៥០.-** បទកាន់កាប់ដោយខុសច្បាប់នូវសម្ភារៈផលិតរូបិយវត្ថុនិងរូបិយបណ្ណ

ការកាន់កាប់ដោយគ្មានការអនុញ្ញាត នូវឧបករណ៍ និងសម្ភារៈដែលជាពិសេស សម្រាប់ធ្វើរូបិយវត្ថុ ឬរូបិយបណ្ណ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៦៥១.-** បទដាក់ឱ្យធ្វើចរាចរណ៍ជាថ្មី នូវរូបិយវត្ថុ និងរូបិយបណ្ណក្លែង

អំពើរបស់បុគ្គលណាដែលបានទទួលរូបិយវត្ថុ ឬរូបិយបណ្ណក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ (បទក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល) និងមាត្រា

៦៤៦ (បទក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល) នៃក្រមនេះ ដោយគិតថាជារូបិយវត្ថុ ឬរូបិយបណ្ណពិត ហើយយកទៅដាក់ឱ្យធ្វើចរាចរណ៍ជាថ្មី ក្រោយពីបានដឹងថាជារបស់ក្លែងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

## មាត្រា ៦៥២.- ការលើកលែងឱ្យរួចផុតពីទោស

បុគ្គលណាដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយ ក្នុងចំណោមបទល្មើសដែលមានចែងក្នុងផ្នែកនេះ នឹងត្រូវបានលើកលែងឱ្យរួចផុតពីទោស ប្រសិនបើបុគ្គលនោះ បានធ្វើឱ្យបទល្មើសនោះមិនបានសម្រេច និងនាំឱ្យដឹងពីអត្តសញ្ញាណជាយថាហេតុរបស់ជនល្មើសផ្សេងៗទៀត ដោយបានឱ្យដំណឹងដល់អាជ្ញាធររដ្ឋបាល ឬតុលាការ ។

## មាត្រា ៦៥៣.- ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៩-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការក្លែងឯកសាររបស់អាជ្ញាធរសាធារណៈ
### ផ្នែកទី ១
### ការក្លែងមូលបត្ររដ្ឋ និងតែមប្រៃសណីយ៍

**មាត្រា ៦៥៤.-** បទក្លែងបន្លំមូលបត្ររដ្ឋនៃព្រះរាជាណាចក្រកម្ពុជា

ការក្លែងបន្លំមូលបត្ររដ្ឋដែលបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ៦៥៥.-** បទក្លែងបន្លំមូលបត្ររដ្ឋបរទេស

ការក្លែងបន្លំមូលបត្ររដ្ឋបរទេស ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៦៥៦.-** បទប្រើប្រាស់មូលបត្ររដ្ឋក្លែង

ការប្រើប្រាស់មូលបត្ររដ្ឋក្លែង ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៦៥៧.-** បទក្លែងបន្ទុំតែមប្រៃសណីយ៍ជាអាទិ៍

ការក្លែងបន្ទុំតែមប្រៃសណីយ៍ ឬផលិតផលដែលមានតម្លៃហិរញ្ញវត្ថុផ្សេងទៀតដែលបោះពុម្ពផ្សាយដោយព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ។

**មាត្រា ៦៥៨.-** បទប្រើប្រាស់តែមប្រៃសណីយ៍ក្លែងជាអាទិ៍

ការប្រើប្រាស់តែមប្រៃសណីយ៍ ឬផលិតផលដែលមានតម្លៃហិរញ្ញវត្ថុផ្សេងទៀតដែលក្លែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល។

**មាត្រា ៦៥៩.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៦៦០.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៩-ការបិទផ្សាយសេចក្ដីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្ដីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## ការក្លែងបន្លំសញ្ញាសម្គាល់របស់អាជ្ញាធរ

**មាត្រា ៦៦១.-** បទក្លែងត្រាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា

ការក្លែងបន្លំត្រាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៦៦២.-** បទប្រើប្រាស់ត្រាក្លែង

ការប្រើប្រាស់ត្រាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជាដែលក្លែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ៦៦៣.-** បទក្លែងក្រដាសដែលមានក្បាលលិខិតផ្លូវការ

ការក្លែងបន្លំក្រដាសដែលមានក្បាលលិខិតផ្លូវការ ប្រើប្រាស់ដោយអាជ្ញាធរសាធារណៈនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល។

**មាត្រា ៦៦៤.-** បទប្រើប្រាស់ក្រដាសក្លែងដែលមានក្បាលលិខិតផ្លូវការ

ការប្រើប្រាស់ក្រដាសក្លែងដែលមានក្បាលលិខិតផ្លូវការ ប្រើប្រាស់ដោយអាជ្ញាធរសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល។

**មាត្រា ៦៦៥.-** បទផលិត ជាអាទិ៍ ក្រដាសពុម្ពដែលបង្កើតឱ្យមានការភ័ន្តច្រឡំ

ការធ្វើ ការលក់ ការចែកចាយ ឬការប្រើប្រាស់ក្រដាសពុម្ពជាមួយនឹងក្រដាសដែលមានក្បាលលិខិតផ្លូវការ ប្រើប្រាស់ដោយអាជ្ញាធរសាធារណៈដែលមានភាពប្រហាក់ប្រហែលគ្នា ដែលអាចបង្កើតឱ្យមានការភ័ន្តច្រឡំនៅក្នុងស្មារតីរបស់សាធារណជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល។

**មាត្រា ៦៦៦.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៦៦៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## គន្ថីទី ៥
## អន្តរប្បញ្ញត្តិ
## ជំពូកតោល
## អន្តរប្បញ្ញត្តិ

**មាត្រា ៦៦៨.-** ការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក

ចំពោះបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសដោយច្បាប់ និង បទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែកផ្សេងទៀតដែលកំពុងនៅជាធរមាន ត្រូវអនុវត្តដោយ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌទាំងនោះ។

នៅក្នុងករណីដែលមានទំនាស់រវាងច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក និងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវអនុវត្តដោយអនុលោមតាមវិធានដែលមានចែងក្នុង គន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ ។

បទប្បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើ មិនត្រូវយកមកអនុវត្ត ចំពោះច្បាប់ ព្រហ្មទណ្ឌដែលមានចរិតពិសេស។

**មាត្រា ៦៦៩.-** ការអនុវត្តនៅក្នុងពេលវេលានូវវិធានស្តីពីអាជ្ញាយុកាលនៃទោស

អាជ្ញាយុកាលនៃទោសចំពោះបទល្មើសដែលត្រូវបានផ្តន្ទាទោស ក្រោយការ ចូលជាធរមាននៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា ៦៧០.-** ការពន្យាតការអនុវត្តគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ

គន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ ត្រូវយកទៅអនុវត្តចំពោះគ្រប់ បទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែកដទៃទៀត លើកលែងតែមានបទប្បញ្ញត្តិផ្សេងចែង ផ្ទុយពីនេះ ។

# គន្ថីទី ៦
# អវសានប្បញ្ញត្តិ
## ជំពូកតែមួយ
## អវសានប្បញ្ញត្តិ

**មាត្រា ៦៧១.-** និរាករណ៍ និងអានុភាពនៃបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុន

ច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុនដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវបាត់បង់អានុភាពចាប់ពីថ្ងៃដែលក្រមនេះ ត្រូវបានអនុវត្ត :

១-រាល់បទប្បញ្ញត្តិព្រហ្មទណ្ឌមុនឆ្នាំ ១៩៩២ ។

២-បទប្បញ្ញត្តិព្រហ្មទណ្ឌនៃបទប្បញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

៣-ច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី ៧ ខែ មករា ឆ្នាំ ២០០២។

បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលមានអានុភាពនៅពេលក្រមនេះ ត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថា គ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ។

ប៉ុន្តែ បទប្បញ្ញត្តិព្រហ្មទណ្ឌពីមុនដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើ ត្រូវបន្តមានអានុភាពអនុវត្តក្រោយការអនុវត្តនៃក្រមនេះ ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តមុនពេលក្រមនេះត្រូវបានអនុវត្ត លើកលែងតែបទប្បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៦៦៨ (ការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក) នៃក្រមនេះ ។

**មាត្រា ៦៧២.-** ការអនុវត្តក្រមនេះ

លើកលែងតែបទប្បញ្ញត្តិទូទៅនៃគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះដែលត្រូវ

យកទៅអនុវត្តភ្លាមក្រោយការចូលជាធរមាននៃក្រមនេះ បទប្បញ្ញត្តិដទៃទៀតត្រូវយកទៅ អនុវត្តក្នុងរយៈពេល ១ ឆ្នាំ ក្រោយការចូលជាធរមាននៃក្រមនេះ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

**ព.ស.០៩១១.១១២៨**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ:១០២៩ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ. ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ឌិនគេន**

# ក្រមព្រហ្មទណ្ឌ
# មាតិកាពិស្តារ

ទំព័រ


**គន្ថីទី ១ បទប្បញ្ញត្តិទូទៅ** - 1 -

**មាតិកាទី ១ ច្បាប់ព្រហ្មទណ្ឌ** ---------------------------- - 1 -

**ជំពូកទី ១ គោលការណ៍ទូទៅ** ---------------------------- - 1 -

**មាត្រា ១.-** ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ--------------- - 1 -

**មាត្រា ២.-** និយមន័យ និងចំណាត់ថ្នាក់នៃបទល្មើស ------- - 1 -

**មាត្រា ៣.-** គោលការណ៍នីត្យានុកូលភាព -------------- - 1 -

**មាត្រា ៤.-** ចេតនាប្រព្រឹត្តបទល្មើស------------------ - 1 -

**មាត្រា ៥.-** ការបកស្រាយច្បាប់ព្រហ្មទណ្ឌ -------------- - 2 -

**មាត្រា ៦.-** ការប្រកាសទោស ------------------------ - 2 -

**មាត្រា ៧.-** លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា ---- - 2 -

**មាត្រា ៨.-** អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាង

នីតិមនុស្សធម៌អន្តរជាតិ ------------------ - 2 -

**ជំពូកទី ២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា** ----------- - 2 -

**មាត្រា ៩.-** ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស ------- - 2 -

**មាត្រា ១០.-** ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬធ្ងន់ជាង--

3 -

**មាត្រា ១១.–** សុពលភាពនៃកិច្ចនីតិវិធី ------------------ - 3 -

**ជំពូកទី ៣ ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ** ----------- - 3 -

**ផ្នែកទី ១ បទល្មើសដែលបានប្រព្រឹត្ត ឬចាត់ថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា** ---------------------- - 3 -

**មាត្រា ១២.–** គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា-- 3 -

**មាត្រា ១៣.–** ទីកន្លែងប្រព្រឹត្តបទល្មើស------------------ - 3 -

**មាត្រា ១៤.–** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា --- - 4 -

**មាត្រា ១៥.–** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស -- - 4 -

**មាត្រា ១៦.–** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា- 4 -

**មាត្រា ១៧.–** ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះអំពើដែលបានចាប់ផ្តើមប្រព្រឹត្តនៅកម្ពុជា---------------- - 4 -

**មាត្រា ១៨.–** ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល ---- - 5 -

**ផ្នែកទី ២ បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា** - 5 -

**មាត្រា ១៩.–** បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ - - 5 -

**មាត្រា ២០.–** ជនរងគ្រោះជាជនជាតិខ្មែរ ---------------- - 5 -

មាត្រា ២១.- ការធ្វើបណ្ដឹងចោទប្រកាន់----------------- - 5 -

មាត្រា ២២.- សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក - 6 -

មាត្រា ២៣.- ការមិនចោទប្រកាន់ត្រួតគ្នា និងទោស ------- - 6 -

មាតិកាទី ២ ការទទួលខុសត្រូវព្រហ្មទណ្ឌ------------------------ - 6 -

ជំពូកទី ១ បទប្បញ្ញត្តិទូទៅ----------------------------------- - 6 -

មាត្រា ២៤.- គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ- 6 -

មាត្រា ២៥.- និយមន័យនៃចារី ------------------------ - 7 -

មាត្រា ២៦.- និយមន័យនៃសហចារី ------------------- - 7 -

មាត្រា ២៧.- និយមន័យនៃការប៉ុនប៉ង------------------ - 7 -

មាត្រា ២៨.- និយមន័យនៃអ្នកផ្ដើមគំនិត ---------------- - 7 -

មាត្រា ២៩.- និយមន័យនៃអ្នកសមគំនិត------------------ - 8 -

មាត្រា ៣០.- និយមន័យនៃអ្នករាជការសាធារណៈ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ------- - 8 -

ជំពូកទី ២ មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ ---------------------- - 9 -

មាត្រា ៣១.- ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី ------------------------------------- - 9 -

មាត្រា ៣២.- ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ--------- - 9 -

**មាត្រា ៣៣.-** ការការពារស្របច្បាប់ -------------------- 10 -

**មាត្រា ៣៤.-** សច្ចធារណ៍នៃការការពារស្របច្បាប់ --------- 10 -

**មាត្រា ៣៥.-** ស្ថានភាពចាំបាច់ ----------------------- 11 -

**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬការបង្ខំ -------------- 11 -

**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ------------ 11 -

**ជំពូកទី ៣ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន** ------------ 11 -

**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ------ 11 -

**មាត្រា ៣៩.-** វិធានការអនុវត្តចំពោះអនីតិជន ------------ 12 -

**មាត្រា ៤០.-** ប្រភេទនៃវិធានការ ---------------------- 12 -

**មាត្រា ៤១.-** ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ- 12

-

**ជំពូកទី ៤ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**------------ 13 -

**មាត្រា ៤២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល --- 13 -

**មាតិកាទី ៣ ទោស** ------------------------------------ 13 -

**ជំពូកទី ១ ប្រភេទនៃទោស** ------------------------------- 13 -

**ផ្នែកទី ១ មូលទោស** ----------------------------------- 13 -

**មាត្រា ៤៣.-** មូលទោស ------------------------------ 13 -

**មាត្រា ៤៤.-** អប្បបរមា និងអតិបរមានៃមូលទោស ------- 13 -

មាត្រា ៤៥.- ការទម្ងន់ទោស និងការសម្រាលទោស ------- 14 -
មាត្រា ៤៦.- និយមន័យនៃបទឧក្រិដ្ឋ ------------------ 14 -
មាត្រា ៤៧.- និយមន័យនៃបទមជ្ឈិម ------------------ 14 -
មាត្រា ៤៨.- និយមន័យនៃបទលហុ ------------------- 14 -
មាត្រា ៤៩.- ការគណនាអំពីថិរវេលានៃទោសដាក់ពន្ធនាគារ -- 14 -
មាត្រា ៥០.- លក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោស ------- 15 -
មាត្រា ៥១.- ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន- 15 -
មាត្រា ៥២.- ផលនៃទោសពិន័យ--------------------- 15 -
ផ្នែកទី ២ ទោសបន្ថែម ------------------------------- 15 -
មាត្រា ៥៣.- ប្រភេទនៃទោសបន្ថែម ------------------ 15 -
មាត្រា ៥៤.- លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម --------- 16 -
មាត្រា ៥៥.- សិទ្ធិពលរដ្ឋដែលអាចដកបាន ------------- 17 -
មាត្រា ៥៦.- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ------- 17 -
មាត្រា ៥៧.- ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ -- 17 -
មាត្រា ៥៨.- ការព្យួរលិខិតបើកបរ ------------------ 17 -

**មាត្រា ៥៩.-** ការហាមឃាត់ចំពោះការស្នាក់នៅទីកន្លែងមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា------------------- 18 -
**មាត្រា ៦០.-** ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ------------------- 18 -
**មាត្រា ៦១.-** ការហាមឃាត់ចំពោះការចូល និងស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដល់ទណ្ឌិតដែលជាជនបរទេស - 19 -
**មាត្រា ៦២.-** ការរឹបអូស--------------------------- 19 -
**មាត្រា ៦៣.-** ការចាត់ចែងទ្រព្យសម្បត្តិរឹបអូស ------------ 19 -
**មាត្រា ៦៤.-** ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ --- 19 -
**មាត្រា ៦៥.-** ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ------- 20 -
**មាត្រា ៦៦.-** ការបិទគ្រឹះស្ថាន ------------------------ 20 -
**មាត្រា ៦៧.-** ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន - 20 -
**មាត្រា ៦៨.-** ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ------- 21 -
**មាត្រា ៦៩.-** ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ----------------------------- 21 -

មាត្រា ៧០.- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមមធ្យោបាយ
ទូរគមនាគមន៍សោតទស្សន៍ ---------------- 21 -
មាត្រា ៧១.- ពេលនៃការអនុវត្តទោសបន្ថែម ------------- 21 -
ផ្នែកទី ៣ ទោសជំនួស ------------------------------- 22 -
កថាភាគទី ១ ការងារសហគមន៍ ------------------------ 22 -
មាត្រា ៧២.- និយមន័យនៃការងារសហគមន៍------------ 22 -
មាត្រា ៧៣.- អ្នកមិនទទួលប្រយោជន៍នៃការងារសហគមន៍--- 22 -
មាត្រា ៧៤.- របបគតិយុត្តនៃការងារសហគមន៍ ---------- 22 -
មាត្រា ៧៥.- គោលការណ៍ជួសជុលការខូចខាតដល់អ្នកដទៃ -- 22 -
កថាភាគទី ២ ការស្តីបន្ទោស ------------------------- 23 -
មាត្រា ៧៦.- របបគតិយុត្តនៃការស្តីបន្ទោស -------------- 23 -
ជំពូកទី ២ ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស ------------ 23 -
ផ្នែកទី ១ ស្ថានទម្ងន់ទោស ---------------------------- 23 -
កថាភាគទី ១ និយមន័យនៃស្ថានទម្ងន់ទោសដោយឡែកខ្លះៗ ----- 23 -
មាត្រា ៧៧.- ក្រុមមានការចាត់តាំង ------------------- 23 -
មាត្រា ៧៨.- ការគិតទុកជាមុន ----------------------- 23 -
មាត្រា ៧៩.- ការកាប់គាស់ទម្លុះទម្លាយ ----------------- 24 -
មាត្រា ៨០.- ការផ្លោះរបងចូល ---------------------- 24 -

**មាត្រា ៨១.-** អាវុធ និងវត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ --- 24 -

**មាត្រា ៨២.-** ការពួនស្នាក់ ------------------------- 24 -

**កថាភាគទី ២ ការមិនរាងចាល** ------------------------- 25 -

**មាត្រា ៨៣.-** អានុភាពនៃការមិនរាងចាល -------------- 25 -

**មាត្រា ៨៤.-** លក្ខខណ្ឌនៃការមិនរាងចាល -------------- 25 -

**មាត្រា ៨៥.-** ការមិនរាងចាលក្នុងបទឧក្រិដ្ឋ ------------- 25 -

**មាត្រា ៨៦.-** ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោស បទឧក្រិដ្ឋ --------------------------- 26 -

**មាត្រា ៨៧.-** ការមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្តន្ទាទោស បទមជ្ឈិម --------------------------- 26 -

**មាត្រា ៨៨.-** ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោស បទមជ្ឈិម --------------------------- 26 -

**មាត្រា ៨៩.-** ការប្រព្ញចបទល្មើស ដើម្បីបង្កើតឱ្យមានការមិនរាងចាល- 27 -

**មាត្រា ៩០.-** ការមិនរាងចាល និងកិច្ចនៃការចោទប្រកាន់ --- 27 -

**មាត្រា ៩១.-** ការមិនរាងចាល និងសេចក្តីសម្រេចស្ថាពរ ---- 27 -

**មាត្រា ៩២.-** បទប្បញ្ញត្តិដោយឡែក ------------------- 27 -

**ផ្នែកទី ២ ស្ថានសម្រាលទោស** ------------------------- 28 -

**មាត្រា ៩៣.-** និយមន័យនៃស្ថានសម្រាលទោស----------- 28 -

មាត្រា ៩៤.- អានុភាពនៃស្ថានសម្រាលទោស ------------- 28 -
មាត្រា ៩៥.- ទោសដាក់ពន្ធនាគារអស់មួយជីវិត
និងស្ថានសម្រាលទោស ------------------ 29 -
ជំពូកទី ៣ របបនៃការប្រកាសទោស ------------------------- 29 -
ផ្នែកទី ១ របបទូទៅ ---------------------------------------- 29 -
មាត្រា ៩៦.- គោលការណ៍ឯកត្តកម្មនៃទោស ------------ 29 -
មាត្រា ៩៧.- ការប្រកាសមូលទោស ------------------- 29 -
មាត្រា ៩៨.- ការប្រកាសទោសជំនួស ------------------ 29 -
មាត្រា ៩៩.- ការប្រកាសទោសបន្ថែមលើមូលទោស -------- 30 -
មាត្រា ១០០.- ការជំនួសមូលទោសដោយទោសបន្ថែម ----- 30 -
មាត្រា ១០១.- វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារ
សហគមន៍ ----------------------------- 30 -
មាត្រា ១០២.- ចិរវេលា និងអំឡុងពេលនៃការងារសហគមន៍- 30 -
មាត្រា ១០៣.- បែបបទនៃការអនុវត្តទោសការងារសហគមន៍ - 31 -
ផ្នែកទី ២ ការព្យួរទោសធម្មតា ----------------------------- 31 -
កថាភាគទី ១ បទប្បញ្ញត្តិរួម ------------------------------ 31 -
មាត្រា ១០៤.- ការប្រកាសការព្យួរទោស ---------------- 31 -
មាត្រា ១០៥.- របបនៃការព្យួរទោស ------------------- 31 -

**កថាភាគទី ២ ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម** ------ 31 -

**មាត្រា ១០៦.-** លក្ខខណ្ឌទាក់ទងនឹងការផ្តន្ទាទោសពីមុន ----- 31 -

**មាត្រា ១០៧.-** ទោសអាចនាំឱ្យមានការព្យួរទោស ---------- 32 -

**មាត្រា ១០៨.-** ការព្យួរទោសមួយផ្នែក ----------------- 32 -

**មាត្រា ១០៩.-** ការដកហូតការព្យួរទោស --------------- 32 -

**មាត្រា ១១០.-** ការមិនដកហូតការព្យួរទោស------------- 32 -

**មាត្រា ១១១.-** ការទុកជាអសារបង់នូវការផ្តន្ទាទោស -------- 32 -

**កថាភាគទី ៣ ការចោទប្រកាន់ចំពោះបទលហុ** ---------------- 33 -

**មាត្រា ១១២.-** លក្ខខណ្ឌទាក់ទងទៅនឹងការផ្តន្ទាទោសពីមុន -- 33 -

**មាត្រា ១១៣.-** ទោសអាចនាំឱ្យមានការព្យួរទោស ---------- 33 -

**មាត្រា ១១៤.-** ការដកហូតការព្យួរទោស --------------- 33 -

**មាត្រា ១១៥.-** ការមិនដកហូតការព្យួរទោស------------- 34 -

**មាត្រា ១១៦.-** ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស ---- 34 -

**ផ្នែកទី ៣ ការព្យួរទោសសាកល្បង** ------------------------ 34 -

**មាត្រា ១១៧.-** និយមន័យ និងលក្ខខណ្ឌនៃការព្យួរទោសសាកល្បង -- 34 -

**មាត្រា ១១៨.-** រយៈពេលនៃការសាកល្បង -------------- 34 -

**មាត្រា ១១៩.-** វិធានការត្រួតពិនិត្យ ------------------- 34 -

**មាត្រា ១២០.-** កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត ----
35 -

**មាត្រា ១២១.-** ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ - 36
-

**មាត្រា ១២២.-** ការដកហូតការព្យួរទោសសាកល្បង --------- 36 -

**មាត្រា ១២៣.-** ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់ -- 37 -

**ផ្នែកទី ៤ ការផ្អាកការប្រកាសទោស** ----------------------- 37 -

**មាត្រា ១២៤.-** លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស------- 37 -

**មាត្រា ១២៥.-** សេចក្តីសម្រេចនៃការផ្អាកការប្រកាសទោស--- 37 -

**មាត្រា ១២៦.-** សវនាការពិនិត្យរឿងដែលបង្អង់ ----------- 38 -

**ផ្នែកទី ៥ របបពាក់កណ្ដាលសេរីភាព** ---------------------- 38 -

**មាត្រា ១២៧.-** លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព------ 38 -

**មាត្រា ១២៨.-** បែបបទនៃរបបពាក់កណ្ដាលសេរីភាព------- 38 -

**មាត្រា ១២៩.-** ការគិតបញ្ចូលរយៈពេលនៃពាក់កណ្ដាលសេរីភាព
ទៅក្នុងទោស --------------------------- 38 -

**មាត្រា ១៣០.-** ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្ដាល
សេរីភាព ---------------------------- 38 -

**មាត្រា ១៣១.-** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត ---------- 39 -

ផ្នែកទី ៦ ការបែងចែកទោសជាប្រភាគ --------------------- 39 -

មាត្រា ១៣២.- លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ --- 39 -

មាត្រា ១៣៣.- បែបបទនៃការបែងចែកទោសជាប្រភាគ ---- 39 -

មាត្រា ១៣៤.- ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ- 39 -

មាត្រា ១៣៥.- ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត--------- 39 -

ជំពូកទី ៤ វិធានអនុវត្តនៅក្នុងករណីបទល្មើសត្រួតគ្នា ----------- 40 -

ផ្នែកទី ១ វិធានទូទៅ ----------------------------------- 40 -

មាត្រា ១៣៦.- បទល្មើសត្រួតគ្នា -------------------- 40 -

មាត្រា ១៣៧.- ការចោទប្រកាន់តែមួយ ---------------- 40 -

មាត្រា ១៣៨.- ការចោទប្រកាន់ដាច់ពីគ្នា -------------- 40 -

ផ្នែកទី ២ វិធានដោយឡែក ---------------------------- 41 -

មាត្រា ១៣៩.- អានុភាពនៃការលើកលែងទោស និងការបន្ធូរបន្ថយ ទោសលើការស្រូបទោស ---------------- 41 -

មាត្រា ១៤០.- ការបូកបញ្ចូលគ្នានៃទោសពិន័យ ---------- 41 -

មាត្រា ១៤១.- ការមិនស្រូបចូលនៃទោសដែលត្រូវបានប្រកាស ចំពោះករណីរត់ចេញពីពន្ធនាគារ ----------- 41 -

ជំពូកទី ៥ មូលហេតុទូទៅដែលមានផលប៉ះពាល់ដល់ការអនុវត្តទោស -- 42 -

**ផ្នែកទី ១ អាជ្ញាយុកាលនៃទោស** --------------------------- 42 -

**មាត្រា ១៤២.-** អានុភាពនៃអាជ្ញាយុកាល --------------- 42 -

**មាត្រា ១៤៣.-** ភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះ

បទឧក្រិដ្ឋមួយចំនួន --------------------- 42 -

**មាត្រា ១៤៤.-** អាជ្ញាយុកាលនៃទោស------------------ 42 -

**មាត្រា ១៤៥.-** ចំណុចចាប់ផ្ដើមនៃថិរវេលា -------------- 42 -

**មាត្រា ១៤៦.-** អាជ្ញាយុកាលនៃកាតព្វកិច្ចរដ្ឋប្បវេណីដែលកើត

ចេញពីសេចក្ដីសម្រេចព្រហ្មទណ្ឌ ----------- 43 -

**ផ្នែកទី ២ ការអនុគ្រោះទោស** --------------------------- 43 -

**មាត្រា ១៤៧.-** អានុភាពនៃការអនុគ្រោះទោស ----------- 43 -

**មាត្រា ១៤៨.-** ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃ

ការអនុគ្រោះទោស --------------------- 43 -

**ផ្នែកទី ៣ ការលើកលែងទោសជាទូទៅ** --------------------- 43 -

**មាត្រា ១៤៩.-** អានុភាពនៃការលើកលែងទោសជាទូទៅ ---- 43 -

**មាត្រា ១៥០.-** ការលើកលែងទោសជាទូទៅ និងការដកការព្យួរទោស-

44 -

**មាត្រា ១៥១.-** ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃ

ការលើកលែងទោសជាទូទៅ -------------- 44 -

**ផ្នែកទី ៤ ការរៀបចំទោស និងការលុបចោលទោសបន្ថែមខ្លះៗ** ---- 44 -

**មាត្រា ១៥២.–** លក្ខខណ្ឌនៃការកែប្រែទោសបន្ថែមខ្លះៗ -----– 44 -

**មាត្រា ១៥៣.–** ការធ្វើឱ្យមានឡើងវិញនូវសិទ្ធិពលរដ្ឋទាំងអស់ ឬខ្លះៗ -– 45 -

**មាត្រា ១៥៤.–** ការរៀបចំកែប្រែ ឬការលុបចោលនូវការហាមឃាត់ -– 45 -

**មាត្រា ១៥៥.–** ការប្រគល់ឱ្យវិញនូវលិខិតបើកបរ ---------– 45 -

**មាត្រា ១៥៦.–** ការកែប្រែវិធានការនៃការហាមឃាត់ចំពោះការស្នាក់នៅ ------------------------------------– 45 -

**មាត្រា ១៥៧.–** ការកែប្រែការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ----------------– 46 -

**មាត្រា ១៥៨.–** ការកែប្រែការហាមឃាត់ការចូលមកក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ------------------– 46 -

**មាត្រា ១៥៩.–** ការកែប្រែការបណ្តេញចេញ ការបិទ ការហាមឃាត់ការធ្វើអាជីវកម្ម -----------------------– 46 -

**ជំពូកទី ៦ ទោសដែលអាចអនុវត្តចំពោះអនីតិជន** ---------------– 47 -

**ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ** -----------------------------– 47 -

**មាត្រា ១៦០.–** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ -----------------------------– 47 -

**មាត្រា ១៦១.–** ទោសបន្ថែម-------------------------– 47 -

**មាត្រា ១៦២.-** ទោសការងារសហគមន៍---------------- - 48 -

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្ដីពីការមិនរាងចាល - 48 -

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស --- 48 -

**មាត្រា ១៦៥.-** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោស សាកល្បង ---------------------------- - 49 -

**ផ្នែកទី ២ បទប្បញ្ញត្តិដោយឡែក** ------------------------- - 49 -

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ -- 49 -

**ជំពូកទី ៧ ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល** -------------- - 50 -

**ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ** ------------------------------ - 50 -

**មាត្រា ១៦៧.-** ទោសដែលត្រូវរងដោយនីតិបុគ្គល --------- - 50 -

**ផ្នែកទី ២ ទោសបន្ថែម** ----------------------------------- - 50 -

**មាត្រា ១៦៨.-** ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល--------- - 50 -

**មាត្រា ១៦៩.-** លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម------ - 51 -

**មាត្រា ១៧០.-** ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល --- 51 -

**មាត្រា ១៧១.-** ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដាន របស់តុលាការ ------------------------ - 51 -

**មាត្រា ១៧២.-** ការហាមឃាត់ចំពោះការធ្វើសកម្មភាព ------ 52 -

**មាត្រា ១៧៣.-** ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ------ 52 -

**មាត្រា ១៧៤.-** ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ ------------------------ 52 -

**មាត្រា ១៧៥.-** ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ------------------------------------ 53 -

**មាត្រា ១៧៦.-** ការបិទគ្រឹះស្ថាន --------------------- 53 -

**មាត្រា ១៧៧.-** ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន --- 53 -

**មាត្រា ១៧៨.-** ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស ------------------------------ 53 -

**មាត្រា ១៧៩.-** ការរឹបអូស និងសិទ្ធិតតិយជន ----------- 54 -

**មាត្រា ១៨០.-** ការបិទផ្សាយសេចក្តីសម្រេច ------------- 54 -

**មាត្រា ១៨១.-** ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍ ------------------ 55 -

**មាត្រា ១៨២.-** ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងរូបវន្តបុគ្គល និងនីតិបុគ្គល --------------------------- 55 -

**គន្ថីទី ២ បទល្មើសប្រឆាំងនឹងបុគ្គល** - 56 -

មាតិកាទី ១ បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម ------------------------------- 56 -

ជំពូកទី ១ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ---------------------- 56 -

មាត្រា ១៨៣.- បទឧក្រិដ្ឋប្រល័យពូជសាសន៍ ------------ 56 -

មាត្រា ១៨៤.- ទោសដែលត្រូវទទួល ------------------ 56 -

មាត្រា ១៨៥.- បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រល័យពូជសាសន៍ -- 56 -

មាត្រា ១៨៦.- ទោសបន្ថែម : ប្រភេទ និងរយៈពេល ---- 57 -

មាត្រា ១៨៧.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល -- 57 -

ជំពូកទី ២ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ---------------------- 59 -

មាត្រា ១៨៨.- បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ------------- 59 -

មាត្រា ១៨៩.- ទោសដែលត្រូវទទួល ------------------ 59 -

មាត្រា ១៩០.- បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ - 60 -

មាត្រា ១៩១.- ទោសបន្ថែម : ប្រភេទ និងរយៈពេល ----- 60 -

មាត្រា ១៩២.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល -- 61 -

ជំពូកទី ៣ បទឧក្រិដ្ឋសង្គ្រាម ----------------------------- 62 -

មាត្រា ១៩៣.- បទឧក្រិដ្ឋសង្គ្រាម --------------------- 62 -

**មាត្រា ១៩៤.-** បទឧក្រិដ្ឋសង្គ្រាមផ្សេងទៀត -------------- 63 -

**មាត្រា ១៩៥.-** ទោសដែលត្រូវទទួល ------------------ 63 -

**មាត្រា ១៩៦.-** បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋសង្គ្រាម ------ 64 -

**មាត្រា ១៩៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល----- 64 -

**មាត្រា ១៩៨.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល --- 65 -

**មាតិកាទី ២ ការប៉ះពាល់ដល់មនុស្ស**--------------------------- 66 -

**ជំពូកទី ១ ការប៉ះពាល់ដល់ជីវិតមនុស្ស** ---------------------- 66 -

**ផ្នែកទី ១ ការប៉ះពាល់ដោយចេតនាដល់ជីវិតមនុស្ស**------------ 66 -

**មាត្រា ១៩៩.-** បទឃាតកម្ម ------------------------ 66 -

**មាត្រា ២០០.-** បទឃាតកម្មគិតទុកជាមុន -------------- 66 -

**មាត្រា ២០១.-** បទឃាតកម្មដោយការប្រើថ្នាំពុល ---------- 67 -

**មាត្រា ២០២.-** បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ------------------------- 67 -

**មាត្រា ២០៣.-** បទឃាតកម្មដែលមានស្ថានទម្ងន់ទោសដោយសារគោលដៅ--------------------------- 67 -

**មាត្រា ២០៤.-** បទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈ- 68 -

**មាត្រា ២០៥.-** បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ ------------------ 68 -

**មាត្រា ២០៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ----- 68 -

**ផ្នែកទី ២ ការប៉ះពាល់ដោយអចេតនាដល់ជីវិតមនុស្ស** ----------- 69 -

**មាត្រា ២០៧.-** បទមនុស្សឃាតដោយអចេតនា ----------- 69 -

**មាត្រា ២០៨.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ----- 69 -

**មាត្រា ២០៩.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល --- 70 -

**ជំពូកទី ២ ការប៉ះពាល់ដល់បូរណភាពនៃបុគ្គល** ----------------- 71 -

**ផ្នែកទី ១ ទារុណកម្ម និងអំពើឃោរឃៅ** ------------------- 71 -

**មាត្រា ២១០.-** បទទារុណកម្ម និងអំពើឃោរឃៅ --------- 71 -

**មាត្រា ២១១.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ --- 71 -

**មាត្រា ២១២.-** ស្ថានទម្ងន់ទោសដោយសារគោលដៅ ------- 72 -

**មាត្រា ២១៣.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងចារី--------- 72 -

**មាត្រា ២១៤.-** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬ ពិការភាព----------------------------- 72 -

**មាត្រា ២១៥.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ -- 73 -

**មាត្រា ២១៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល ----- 73 -

**ផ្នែកទី ២ អំពើហិង្សា** ---------------------------------- 74 -

**មាត្រា ២១៧.-** បទហិង្សាដោយចេតនា ----------------- 74 -

**មាត្រា ២១៨.–** ស្ថានទម្ងន់ទោស --------------------- 74 -

**មាត្រា ២១៩.–** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ -- 74 -

**មាត្រា ២២០.–** ស្ថានទម្ងន់ទោសដោយសារគោលដៅ ------ 75 -

**មាត្រា ២២១.–** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនល្មើស --- 75 -

**មាត្រា ២២២.–** អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន - 75 -

**មាត្រា ២២៣.–** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬ ពិការភាព---------------------------- 76 -

**មាត្រា ២២៤.–** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ - 76 -

**មាត្រា ២២៥.–** ការចាត់ទុកការប្រើសារជាតិពុលដូចជាអំពើហិង្សា ដោយចេតនា ------------------------- 76 -

**មាត្រា ២២៦.–** ការចាត់ទុកការផ្តល់អាហារដែលមានសារជាតិពុល ដូចជាអំពើហិង្សាដោយចេតនា------------- 76 -

**មាត្រា ២២៧.–** ការចាត់ទុកការបញ្ចូលសារជាតិពុលក្នុងទឹកសម្រាប់ បរិភោគដូចជាអំពើហិង្សាដោយចេតនា------- 76 -

**មាត្រា ២២៨.–** បទហិង្សាស្រាល--------------------- 77 -

**មាត្រា ២២៩.–** ទោសបន្ថែម : ប្រភេទ និងរយៈពេល ---- 77 -

**មាត្រា ២៣០.–** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល -- 78 -

ផ្នែកទី ៣ ការគំរាមកំហែង --------------------------- - 79 -
មាត្រា ២៣១.- បទគំរាមកំហែង -------------------- - 79 -
មាត្រា ២៣២.- បទគំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ------------------------------ - 80 -
មាត្រា ២៣៣.- បទគំរាមកំហែងថានឹងសម្លាប់ ----------- - 80 -
មាត្រា ២៣៤.- បទគំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញ លក្ខខណ្ឌអ្វីមួយ --- - 80 -
មាត្រា ២៣៥.- ទោសបន្ថែម : ប្រភេទ និងរយៈពេល ---- - 80 -
ផ្នែកទី ៤ ការបង្កឱ្យមានរបួសដោយអចេតនា ----------------- - 81 -
មាត្រា ២៣៦.- បទបង្កឱ្យមានរបួសដោយអចេតនា -------- - 81 -
មាត្រា ២៣៧.- ទោសបន្ថែម : ប្រភេទ និងរយៈពេល ---- - 82 -
